UCCBT
UTAH CAMBODIAN COMMUNITY BUDDHIST TEMPLE

# Cambodian New Year Celebration
# Year of the Horse 2558/2014

*The honorable monks and the board members of the temple committee of Wat Buddhikaram of Utah (UCCBT), would like to cordially invite you, your family, devotees and friends to join us in greeting the Khmer New Year celebration.*

## Program for the New Year festival

***Friday, April 11th 2014***:

*LOCATION:* Wat Buddhikaram (UCCBT) 3325W 3800S WVC, UT 84119

TEL: (801)968-9073; (801)865-3386; (801)703-7269; (801)631-4423

- *6:00 PM*
  - Begin Evening Chanting and Precepts
  - Honor the Precious Triple Gems

***Saturday, April 12th 2014***:

*LOCATION: Miss Saigon Reception Center 2644 W 2365 S WVC, UT 84119*

- *9:00 AM*
  - Honor the Three Precious Gems
  - Observe and Listen to the Monks Chanting and Precepts of Dharma Buddhist Talk
  - Bang Skol (transferring merits to the spirits of our ancestors)
  - Bowl Offering and Lunch Offering to the Monks
  - Lunch to the Devotees and Participants

- *Afternoon Entertainments and Activities*
  - Presentation of Cambodian Traditional Dances, directed by Mr. Chanda Chuon
  - Miss Cambodian Utah Pageant
  - Men and Women's Dancing
  - Children Fashion Show
  - Ladies Khmer Traditional Wear Fashion Show
  - Talent Show
  - Singing (Special Guest )
- *Evening*
  - Entertainment, music, and dancing until midnight

*Note: We are selling prepared foods and drinks for fundraising all day Saturday.*

***<u>Sunday, April 13th 2014</u>:***

*LOCATION: Wat Buddhikaram (UCCBT) 3325 W 3800 S WVC, UT 84119*

- *<u>9:00 AM</u>*
  - Honor the Three Precious Gems
  - Observe and Listen to the Monks Chanting and Precepts of Dharma Buddhist Talk
  - Bang Skol (transferring merits to the spirits of our ancestor)
  - Bowl Offering and Lunch Offerings to the Monks
  - Lunch to the Devotees and Participants
  - Divinity of Buddha, Sprinkling Holy Water on Buddha Images
  - Setting up Sand Mounts (the atonement of wrongdoing)
  - End of Ceremonies

*Happy New Year!!! We wish you the best prosperities, increasing good fortune, and benedictory*

*Thank you,*

*The Honorable Monks and the Committee of Wat Buddhikaram of Utah*

# ~សួស្តីឆ្នាំថ្មី~

## ឆ្នាំ មមី ឆស័ក ព.ស.២៥៥៨ គ.ស.២០១៤

*ខ្ញុំព្រះករុណា អាត្មាភាព យើងខ្ញុំ ជាព្រះគ្រូចៅអធិការ ប្រធានគណៈកម្មការ គណកម្មការ អាចារ្យ វត្តពុទ្ធិការាមរដ្ឋយូថាហ៍បានព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទប្រារព្ធធ្វើ***ពិធីបុណ្យចូលឆ្នាំថ្មី** *តាមទំនៀមទំលាប់ប្រពៃណីជាតិខ្មែរ គឺឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨ គ.ស. ២០១៤ ។*

*អាស្រ័យដូចបានចម្រើនពរ ជំរាបជូនខាងលើនេះ សូមចម្រើនពរ គោរពអញ្ជើញ ឧបាសក ឧបាសិកាលោក លោកស្រី យុវជន យុវតី កុមារ កុមារី អ្នកនាង កញ្ញា សាធុសប្បុរសទាំងឡាយ មេត្តាអញ្ជើញចូលរួមក្នុងពិធីនេះឲ្យបានអធិកអធមសមរម្យរុងរឿងនឹងបានបំពេញ នូវកងការមហាកុសលបង្សុកូលឧទ្ទិសមគ្គផលដល់បុព្វការីជនដែលបានចែកឋានទៅ កាន់លោកខាងមុខ ជាពិសេសបានទទួលនូវពរសីពរលោកជ័យមង្គលសួស្តីសិរីមហាប្រសើរអំពីទេវតាឆ្នាំថ្មី ដូចមានកាលបរិច្ឆេទនិងកម្មវិធីខាងក្រោមនេះ។*

**កម្មវិធីបុណ្យថ្ងៃសុក្រ**(ថ្ងៃទី១ ថ្ងៃចូលឆ្នាំ) ប្រារព្ធធ្វើនៅ **វត្តពុទ្ធិការាម (Wat Buddhikaram)**

**Utah Cambodian Community Buddhist Temple (UCCBT)**
**3325W 3800S, WVC, UT 84119 ☎ (801) 968-9073or(801)865-3386; (801)703-7269; (801)631-4423**

*☞ថ្ងៃ សុក្រ ១៤កើត ខែ ចេត្រ ឆ្នាំ មមី ឆស័ក ព.ស.២៥៥៨ ត្រូវនឹងថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០១៤វេលាម៉ោង៦:០០ រសៀល ជួបជុំពុទ្ធបរិស័ទនៅវត្ត ធ្វើបទនមស្សការព្រះរតនត្រ័យ សមាទានសីល និមន្តព្រះសង្ឃចម្រើនព្រះបរិត្តសូត្រ ឧទ្ទិសមគ្គផល ជាកិច្ចចាប់ផ្តើមបុណ្យថ្ងៃទី១។*

**កម្មវិធីបុណ្យថ្ងៃសៅរ៍** (ថ្ងៃទី២ វារៈវ័នបត) ប្រារព្ធធ្វើនៅ

**Miss Saigon Reception Center**
**2644West 2365South, West Valley City, UT**

*☞ថ្ងៃ សៅរ៍ ១៣កើត ខែ ចេត្រ ឆ្នាំ មមី ឆស័ក ព.ស.២៥៥៨ ត្រូវនឹងថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៤វេលាម៉ោង៩:០០ ជួបជុំពុទ្ធបរិស័ទធ្វើបទនមស្សការព្រះរតនត្រ័យ សមាទានសីល រាប់បាត្រ វេរចង្ហាន់ប្រគេនព្រះសង្ឃ បង្សុកូល ឧទ្ទិសមគ្គផល ដល់លោកអ្នកដ៏មានគុណនិង ញាតកាទាំង៧សន្តាន។*

*បន្ទាប់ពីអស់លោកអ្នកទទួលទានអាហារថ្ងៃត្រង់រួចហើយ នឹងមានកម្មវិធីពិសេសបន្ត កំសាន្តតទៅទៀតៈ*

*១-របាំប្រពៃណីខ្មែរ សម្តែងដោយរបាំប្រចាំវត្តពុទ្ធិការាម ដឹកនាំដោយលោក* **ចន្ថា ជិន**

*២-ការប្រឡងជ្រើសរើស បវរកញ្ញា*

*៣-របាំ សម្តែងដោយ ស្រ្តី*

*៤-របាំ សម្តែងដោយ បុរស*

*៥-ការបង្ហាញម៉ូតសំលៀកបំពាក់របស់ខ្មែរ សម្តែងដោយ កុមារា កុមារី*

*៦-ការបង្ហាញម៉ូតសំលៀកបំពាក់របស់ខ្មែរ បង្ហាញដោយ ស្រ្តី*

*៧-បង្ហាញទេពកោសល្យ របស្សកម្ម របស់អ្នកសម្តែងផ្សេងៗ*

*៨-អាមេរិកាំងតន្ត្រី ប្រគំជាបទភ្លេងខ្មែរ និង ច្រៀងជាភាសាខ្មែរ។*

*បន្ទាប់ទៀត មានការច្រៀង រាំកំសាន្ត រហូតដល់ម៉ោង ១២:០០ កណ្តាលអាធ្រាត្រ ទើបបិទកម្មវិធី។*

**សូមបញ្ជាក់ជាពិសេសថា** :

*នៅកន្លែងនោះ យើងខ្ញុំមានលក់ បុកល្ហុង សាច់គោអាំង និង នំចំណីផ្សេងៗទៀតជាច្រើនផងដែរ។*

**កម្មវិធីបុណ្យថ្ងៃអាទិត្យ** *(ថ្ងៃទី៣ វារៈឡើងស័ក)* *ប្រារព្ធធ្វើនៅ* **វត្តពុទ្ធិការាម**

☞ *ថ្ងៃអាទិត្យ ១៤កើត ខែ ចេត្រ ឆ្នាំ មមី ឆស័ក ពស ២៥៥៨ ត្រូវនឹងថ្ងៃទី ១៣ ខែ មេសា ឆ្នាំ២០១៤*

*វេលាម៉ោង ៩:០០ ព្រឹក ជួបជុំពុទ្ធបរិស័ទ ញាតិមិត្រជិតឆ្ងាយនៅវត្ត ធ្វើបទនមស្សការ ព្រះរតនត្រ័យសមាទានសីល រាប់បាត្រ វេរចង្ហាន់ប្រគេនព្រះសង្ឃ។ ស្វាធ្យាយ ពហូ ទេវា ដារ បង្សុកូល ឆ្លង និង ឧទ្ទិសមហាកុសល ជូនលោកអ្នកដ៏មានគុណ ដែលបានចែកឋានទៅ កាន់លោកខាងមុខ។*

*បន្ទាប់ពីបានទទួលទានអាហារពេលថ្ងៃត្រង់រួចហើយ មានប្រារព្ធកម្មវិធីជាបន្តទៀតគឺ ពិធីស្រង់ព្រះសុគន្ធវារីព្រះពុទ្ធរូប ពិធីពូនភ្នំខ្សាច់ បូជាដល់ព្រះចូឡាមណីចេតិយ ដើម្បីស្មារលានូវកម្មពៀរវេរាទាំងឡាយនិង ឧទ្ទិសនូវកងការមហាកុសលដល់បុព្វការីជន ដែលបានចែកឋានទៅកាន់លោកខាងមុខ ជាកិច្ចបញ្ចប់កម្មវិធីបុណ្យចូលឆ្នាំថ្មី។*

*សូមគំនរលោកជ័យ មង្គលសួស្តី សិរីមហាប្រសើរ និង ពរទាំងឡាយ៥ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ សូមកើតមានដល់ ឧបាសក ឧបាសិកា លោក លោកស្រី អ្នកនាង កញ្ញា និង សាធុសប្បុរសទាំងឡាយ នៅក្នុងសកលលោកទាំងមូលនេះ ឲ្យបានគ្រប់ៗគ្នា កុំបីអាក់ខានឡើយ៕ សូមអនុមោទនាបុណ្យ ! សូមអរព្រះគុណនិងសូមអរគុណ !*